ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយ
# ស្តីពី
# កម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ

# POLICY
# ON
# NON-FORMAL EDUCATION EQUIVALENCY PROGRAMME

២០០៨

# អារម្ភកថា

យោងតាមច្បាប់ស្តីពីការអប់រំ ជំពូកទី ៤ មាត្រា ១៥ បានកំណត់អំពីប្រព័ន្ធអប់រំពេញលេញ និងឯកភាពថា៖ *រដ្ឋត្រូវរៀបចំឱ្យមានប្រព័ន្ធអប់រំពេញលេញ និងឯកភាព ដែលរួមមានការអប់រំក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ* ។

គោលនយោបាយស្តីពីកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធនៅកម្ពុជា បានបង្ហាញពីដំណាក់កាលកំណែទម្រង់មួយនៃការអប់រំក្រៅប្រព័ន្ធរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបម្រើសេវាកម្មអប់រំនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីឈានទៅរកបរិបទថ្មីនៃសាកលភាវូបនីយកម្ម។

កម្មវិធីសមមូល គឺជាសមាសភាគដ៏សំខាន់មួយនៃកម្មវិធីអប់រំក្រៅប្រព័ន្ធ។ យន្តការនៃកម្មវិធីនេះ គឺផ្តល់សំណាង និងឱកាសជាថ្មីដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបដែលពុំមានឱកាសរៀនសូត្រនៅតាមសាលារៀនអប់រំក្នុងប្រព័ន្ធអាចបន្តការរៀនសូត្រជាថ្មីម្តងទៀត ដែលជាផ្លូវឆ្ពោះទៅរកការសិក្សាពេញមួយជីវិត និងឈានទៅរកពិភពការងារបានពេញលេញ។

គោលនយោបាយនេះ ក៏ជាមាគ៌ាដ៏ចម្បង និងត្រឹមត្រូវតាមនិន្នាការនៃពិភពលោក ដែលជាយុទ្ធសាស្ត្រ និងជាចំណុចដៅរបស់ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា។ គោលនយោបាយនេះ ក៏បានបើកចំហវិសាលភាពនៃតម្រូវការអប់រំនៅកម្ពុជាឱ្យកាន់តែទូលំទូលាយ មានលក្ខណៈពហុរូបភាព និងពហុវិស័យក្នុងការសិក្សារៀនសូត្រនៅគ្រប់កម្រិតថ្នាក់ចាប់ពីបឋមសិក្សារហូតដល់មធ្យមសិក្សា។ ការសិក្សាអប់រំបែបនេះ គឺជាតម្រូវការចាំបាច់ក្នុងការលើកកម្ពស់ជីវភាពរស់នៅឱ្យកាន់តែមានភាពប្រសើរ រួមចំណែកសម្រេចផែនការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

គោលនយោបាយនេះ ធានាផ្តល់ការអប់រំដល់ប្រជាពលរដ្ឋគ្រប់រូបឱ្យទទួលបានដោយស្មើភាពនូវការសិក្សាពេញមួយជីវិតប្រកបដោយគុណភាព ព្រមទាំងត្រៀមលក្ខណៈជូនពួកគាត់ឱ្យបំពេញតួនាទីដ៏សកម្មមួយនៅក្នុងការកសាងប្រទេសជាតិ សំដៅធ្វើសមាហរណកម្មកម្ពុជាទៅក្នុងសហគមន៍អន្តរជាតិ។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍ ដែលបានចូលរួមគាំទ្រយ៉ាងសកម្មដល់ការងារអប់រំក្រៅប្រព័ន្ធ ក៏ដូចជាការកសាងគោលនយោបាយស្តីពីកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធនេះ ។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមយ៉ាងមុតមាំថា គោលនយោបាយស្តីពីកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ នឹងរួមចំណែកអភិវឌ្ឍធនធានមនុស្សនៅកម្ពុជាប្រកបដោយគុណភាព និង ចីរភាព។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ [illegible] ឆ្នាំ ២០០៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**អ៊ឹម សិទ្ធី**

# មាតិកា


អារម្ភកថា ........................................ ១

I-សាវតារ ........................................ ៣

II-គោលបំណង ........................................ ៤

III-ក្របខណ្ឌសកម្មភាព និងវិសាលភាព ........................................ ៥

១-ក្របខណ្ឌសកម្មភាព

២-វិសាលភាព

IV-យុទ្ធសាស្ត្រ និងវិធានការអនុវត្ត ........................................ ៥

១-យុទ្ធសាស្ត្រទី ១

២-យុទ្ធសាស្ត្រទី ២

៣-យុទ្ធសាស្ត្រទី ៣

V-កម្មវិធីសិក្សា ........................................ ៧

១-កម្មវិធីសិក្សាសមមូលបឋមសិក្សា

២- កម្មវិធីសិក្សាសមមូលមធ្យមសិក្សាបឋមភូមិ

៣- កម្មវិធីសិក្សាសមមូលមធ្យមសិក្សាទុតិយភូមិ

VI-ការរៀបចំសាលារៀនកម្មវិធីសមមូល ........................................ ៩

១-សាលារៀនកម្មវិធីសមមូល

២-រយៈពេល និងថ្នាក់រៀនកម្មវិធីសមមូល

៣-ការអនុញ្ញាតឱ្យបង្កើតសាលារៀនសមមូល

៤-លក្ខខណ្ឌនៃការចូលរៀន

៥-គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន

៦-រូបភាពរៀនសូត្រ

ឧបសម្ព័ន្ធ

# I-សារតារ

គោលនយោបាយស្តីពីការងារអប់រំក្រៅប្រព័ន្ធរបស់រាជរដ្ឋាភិបាល លេខ ០១ គនរ. ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០២ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ និងដ៏ឈ្លាសវៃរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានកំណត់ថា *រាជរដ្ឋាភិបាលបានចាត់ទុកការងារអប់រំក្រៅប្រព័ន្ធ ជាប្រព័ន្ធអប់រំផ្លូវការមួយនៃព្រះរាជាណាចក្រកម្ពុជា ដូចជាការអប់រំក្នុងប្រព័ន្ធដែរ។* ដើម្បីអនុវត្តឱ្យបានជោគជ័យផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ២០០៣-២០១៥ របស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និង កីឡាបានរៀបចំនូវកម្មវិធីថ្មីមួយ គឺកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធក្នុងគោលបំណងច្បាស់លាស់ដើម្បីផ្តល់ឱកាសឱ្យប្រជាពលរដ្ឋគ្រប់រូបបានរៀនសូត្រពេញមួយជីវិត។

ការងារកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ ជាភារកិច្ចមួយថ្មីរបស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ដូចនេះហើយ ទើបក្រសួងអប់រំ យុវជន និងកីឡាបានបញ្ជូនមន្ត្រីមួយចំនួននៃនាយកដ្ឋានទៅធ្វើទស្សនកិច្ចសិក្សាស្រាវជ្រាវដកពិសោធន៍អំពីការងារនេះពីបណ្តាប្រទេសមួយចំនួននៅក្នុងតំបន់ដូចជាប្រទេសហ្វីលីពីន ប្រទេសថៃ ប្រទេសឥណ្ឌាជាដើម។

ក្រោយពីបានធ្វើទស្សនកិច្ចសិក្សារួចមក និងដោយមានអង្គការជាតិ អន្តរជាតិជួយឧបត្ថម្ភទាំងផ្នែកបច្ចេកទេស និងថវិកាផងនោះ ពិសេសពីអង្គការយូណេស្កូ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ក៏បានផ្តើមធ្វើការប្រជុំពិភាក្សាអំពីកម្មវិធីសមមូលជាលើកទី ១ នៅសាលប្រជុំនៃនាយកដ្ឋានបឋមសិក្សាពីថ្ងៃទី ២០ ដល់ទី ២១ ខែ ធ្នូ ឆ្នាំ ២០០៤។ លើកទី ២ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធក៏បានផ្តើមរៀបចំសិក្ខាសាលានៅខេត្តស្វាយរៀងពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៥ ដើម្បីផ្លាស់ប្តូរយោបល់លើការងារកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ។ លើកទី ៣ យើងបានធ្វើការប្រជុំពិភាក្សាអំពីកម្មវិធីសមមូលនេះនៅសាលប្រជុំនៃនាយកដ្ឋានបឋមសិក្សា ថ្ងៃទី ២២-២៣ ខែ កុម្ភៈ ឆ្នាំ ២០០៦។

ដោយយល់ឃើញថាការងារសមមូលអប់រំក្រៅប្រព័ន្ធនេះ មានដំណើរការយឺតនិងពុំទាន់សភាពការណ៍ ក្រសួងអប់រំ យុវជន និង កីឡា ក៏បានបង្កើតគណៈកម្មការពន្លឿនកម្មវិធីសមមូលថ្នាក់ក្រសួងមកជួយនាយកដ្ឋានជំនាញតាមរយៈលិខិតឧទ្ទេសនាមលេខ ៣៥៦៤ អយក.ឧទន. ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៧។ គណៈកម្មការពន្លឿនកម្មវិធីសមមូលបានរៀបចំជាសេចក្តីព្រាងគោលនយោបាយរួចជាស្រេចនៅ

ដើមខែ តុលា ឆ្នាំ ២០០៧ មានឈ្មោះថា *គោលនយោបាយស្តីពីកម្មវិធីសមមូលចំណេះទូទៅ* ដែលមាន ២៣ ទំព័រ ។ នៅចុងខែតុលា ឆ្នាំ ២០០៧ សេចក្តីព្រាងគោលនយោបាយនេះបានយកមកប្រជុំឆ្លងយោបល់ក្នុងនាយកដ្ឋានអប់រំក្រៅប្រព័ន្ធដោយរក្សាឈ្មោះនៅដដែល មាន ២២ ទំព័រ ។

លើកទី ២ សេចក្តីព្រាងគោលនយោបាយនេះបានដាក់ឆ្លងក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពីកម្មវិធីសមមូលពីថ្ងៃទី ២ ដល់ទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ដោយមានការឧបត្ថម្ភពីសហគមន៍អឺរ៉ុប និងអង្គការយូណេស្កូ ។ ជាលទ្ធផលអង្គសិក្ខាសាលាបានប្តូរឈ្មោះពីគោលនយោបាយស្តីពីកម្មវិធីសមមូលចំណេះទូទៅ ទៅជា *គោលនយោបាយស្តីពីកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ* ដែលមាន ២២ ទំព័រ ។ ដោយផ្អែកលើលទ្ធផលនៃសិក្ខាសាលា នៅដើម ខែធ្នូ ឆ្នាំ ២០០៧ យើងក៏បានពិនិត្យនិងកែលំអខ្លឹមសារ និងបានដាក់ឆ្លងអង្គប្រជុំនៃថ្នាក់ដឹកនាំនាយកដ្ឋានអប់រំក្រៅប្រព័ន្ធដើម្បីធ្វើការពិនិត្យ និងកែសម្រួលមានត្រឹមតែ ១២ ទំព័រវិញ ។ លើកទី៣ សេចក្តីព្រាងនេះត្រូវបានដាក់ឆ្លងអង្គប្រជុំនៃអគ្គនាយកដ្ឋានអប់រំ ។

## II-គោលបំណង

កម្មវិធីសមមូល គឺជាកម្មវិធីអប់រំក្រៅប្រព័ន្ធមួយដែលមានតម្លៃសមមូលនឹងកម្មវិធីអប់រំក្នុងប្រព័ន្ធ ។ ខ្លឹមសារនៃកម្មវិធីនេះ គឺបានជ្រើសសម្រាំងចេញពីខ្លឹមសារសំខាន់ៗនៃកម្មវិធីសិក្សាចំណេះទូទៅដោយផ្សារភ្ជាប់ទៅនឹងកម្មវិធីបណ្តុះបណ្តាលជំនាញមុខរបរចាំបាច់សម្រាប់ប្រកបការងារចិញ្ចឹមជីវិត ក្នុងគោលបំណងដូចខាងក្រោម :

**១.** ផ្តល់ឱកាសជាថ្មីដល់កុមារ យុវជន មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ កម្មករនិយោជិត និងមនុស្សពេញវ័យទាំងអស់ដែលមិនមានឱកាសរៀននៅសាលារៀនអប់រំក្នុងប្រព័ន្ធអាចចូលរៀនបន្តការសិក្សា និងបញ្ចប់ដោយជោគជ័យតាមកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធនៅគ្រប់ភូមិសិក្សា ។

**២.** ផ្តល់វិញ្ញាបនបត្រ ឬសញ្ញាបត្រសមមូលនឹងផ្នែកអប់រំក្នុងប្រព័ន្ធ ដល់សិស្សដែលប្រឡងជាប់បញ្ចប់ភូមិសិក្សានីមួយៗ ។

**៣.** អភិវឌ្ឍធនធានមនុស្សដើម្បីរួមចំណែកសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នាប្រកបដោយគុណភាព ។

## III-ក្របខ័ណ្ឌសកម្មភាព និងវិសាលភាព

### ១-ក្របខ័ណ្ឌសកម្មភាព

គោលនយោបាយស្តីពីកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ ស្ថិតក្នុងក្របខ័ណ្ឌនៃការអប់រំបន្ត និងជំនួសឱ្យកម្មវិធីបំពេញវិជ្ជាដែលមានបច្ចុប្បន្ន។ កម្មវិធីសមមូលនេះ គឺសំដៅឆ្លើយតបទៅនឹងតម្រូវការរៀនសូត្រនៃប្រជាពលរដ្ឋគ្រប់រូប ទាំងកុមារ និងយុវជនដែលនៅក្រៅសាលារៀន មន្ត្រីរាជការគ្រប់ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ និងកម្មករ និយោជិត ដែលបម្រើការក្នុងរោងចក្រ សហគ្រាស។ កម្មវិធីសមមូលនេះមានលក្ខណៈមិនពេញម៉ោង និងទន់ភ្លន់ សម្រាប់បឋមសិក្សា និងមធ្យមសិក្សាដែលកំពុងត្រូវការជាបន្ទាន់ ហើយបំពេញឱ្យការអប់រំក្នុងប្រព័ន្ធ ប៉ុន្តែវាមានទិសដៅប្រើប្រាស់វិធីសាស្ត្រ ដែលមានភាពទន់ភ្លន់ក្នុងការផ្តល់ឱកាសឱ្យពួកគេមានលទ្ធភាពរៀនផង និងប្រកបមុខរបរចិញ្ចឹមជីវិតផង។ ចំពោះកុមារចុះឈ្មោះចូលរៀនយឺត នឹងទទួលបានការអប់រំតាមរយៈកម្មវិធីអប់រំចូលរៀនយឺត។

### ២-វិសាលភាព

គោលនយោបាយស្តីពីកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ ត្រូវបានកំណត់ច្បាស់លាស់អំពីក្រុមមុខសញ្ញា និងទីតាំងពិតប្រាកដដែលគ្របដណ្តប់ទូទាំងប្រទេសនៅគ្រប់ទីកន្លែងដែលមានតម្រូវការរៀនសូត្រ។

## IV-យុទ្ធសាស្ត្រ និងវិធានការអនុវត្ត

ដើម្បីអនុវត្តគោលនយោបាយស្តីពីកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ ឱ្យទទួលបានជោគជ័យ តម្រូវឱ្យមានយុទ្ធសាស្ត្រ និងវិធានការអនុវត្តច្បាស់លាស់តាមការកំណត់ដូចខាងក្រោម ៖

**-យុទ្ធសាស្ត្រទី ១ :** បង្កលក្ខណៈឱ្យកុមារ និងយុវជននៅក្រៅសាលារៀន និងសិស្សបោះបង់ការសិក្សាគ្រប់កម្រិតថ្នាក់ឱ្យបានចូលរៀន។

***. វិធានការអនុវត្ត :***

-ផ្សព្វផ្សាយអំពីគោលនយោបាយនៃកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធដល់សហគមន៍ អង្គភាព រោងចក្រ សហគ្រាស និងអាជ្ញាធរមូលដ្ឋាន។

-ចេញសេចក្តីណែនាំអនុវត្តដល់មន្ទីរ ការិយាល័យអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ស្រុក-ខណ្ឌ និងផ្នែកពាក់ព័ន្ធក្នុងការប្រមូលកុមារ និងយុវជនដែលនៅក្រៅសាលារៀន ឱ្យបានចូលរៀននៅថ្នាក់កម្មវិធីសមមូល ។

-អំពាវនាវឱ្យមានការចូលរួមពីសហគមន៍ អាណាព្យាបាល សប្បុរសជន និងដៃគូអភិវឌ្ឍន៍ជួយឧបត្ថម្ភគាំទ្រកម្មវិធីសមមូល ។

-រៀបចំលិខិតបទដ្ឋានសម្រាប់ដំណើរការកម្មវិធី ។

-ថវិកាទ្រទ្រង់ដំណើរការសិក្សានៅកម្រិតសមមូលបឋមសិក្សា និងកម្រិតសមមូលមធ្យមសិក្សាបឋមភូមិត្រូវអនុវត្តតាមសេចក្តីណែនាំជាផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

- **យុទ្ធសាស្ត្រទី ២ :** បង្កលក្ខណៈឱ្យប្រជាពលរដ្ឋ មន្ត្រីរាជការ កម្មករនិយោជិត និងកងកម្លាំងប្រដាប់អាវុធដែលមានសញ្ញាបត្រសមមូលមធ្យមសិក្សាបឋមភូមិបានបន្តការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ ។

***វិធានការអនុវត្ត :***

-ផ្សព្វផ្សាយអំពីគោលនយោបាយនៃកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធជូនដល់ប្រជាពលរដ្ឋ មន្ត្រីរាជការនៅគ្រប់ស្ថាប័ន កម្មករ និយោជិត តាមរោងចក្រសហគ្រាស និងកងកម្លាំងប្រដាប់អាវុធដែលមានសញ្ញាបត្រសមមូលមធ្យមសិក្សាបឋមភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ ។

-ផ្សព្វផ្សាយអំពីផលប្រយោជន៍នៃការសិក្សានៅក្នុងកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធ ។

-បង្កលក្ខណៈមុខសញ្ញាខាងលើឱ្យចូលរៀនជាបន្តបន្ទាប់ សមស្របតាមពេលវេលា និងទីកន្លែង ។

-អំពាវនាវឱ្យមានការចូលរួមពីសហគមន៍ អាណាព្យាបាល សប្បុរសជន និងដៃគូអភិវឌ្ឍន៍ជួយឧបត្ថម្ភគាំទ្រកម្មវិធីសមមូល ។

-រៀបចំលិខិតបទដ្ឋានសម្រាប់ដំណើរការកម្មវិធី ។

-ថវិកាទ្រទ្រង់ដំណើរការសិក្សានៅកម្រិតសមមូលមធ្យមសិក្សាទុតិយភូមិ ត្រូវអនុវត្តតាមសេចក្តីណែនាំជាផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**-យុទ្ធសាស្ត្រទី ៣ :** ការវាយតម្លៃបញ្ចប់កម្រិតសិក្សា។

***.វិធានការអនុវត្ត :***

-ចំពោះសមមូលបឋមសិក្សា អនុវត្តការធ្វើតេស្តបញ្ចប់ថ្នាក់ឆ្នាំទី ២ ។

-ចំពោះសមមូលមធ្យមសិក្សា ការវាយតម្លៃបញ្ចប់កម្រិតសិក្សា ដោយអនុវត្តការប្រឡង រួមមាន :

+ការប្រឡងឆមាសទី១ ឆមាសទី២។

+ការប្រឡងសញ្ញាបត្រសមមូលមធ្យមសិក្សាបឋមភូមិ និងសញ្ញាបត្រសមមូលមធ្យមសិក្សាទុតិយភូមិ។

-ការរៀបចំ និងការប្រព្រឹត្តិទៅនៃការប្រឡង នឹងមានចែងក្នុងសេចក្តីណែនាំលំអិតរបស់ក្រសួងអប់រំ យុវជន និងកីឡា។

-ថវិកាទ្រទ្រង់ប្រឡងសញ្ញាបត្រសមមូលមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិជាបន្ទុករបស់ក្រសួងអប់រំ យុវជន និងកីឡា។

## V-កម្មវិធីសិក្សា

-កម្មវិធីសិក្សានៃកម្មវិធីសមមូលមានខ្លឹមសារសំខាន់ៗពីរ : (១)ខ្លឹមសារដែលជ្រើសសម្រាំងចេញពីកម្មវិធីសិក្សានៃការអប់រំក្នុងប្រព័ន្ធ ប្រមាណ ៧០% និង (២) ខ្លឹមសារបំណិនជីវិត ប្រមាណ ៣០%។

-ការសិក្សាក្នុងមួយឆ្នាំមានយ៉ាងតិចស្មើនឹង ៣៨ សប្តាហ៍ និងក្នុងមួយសប្តាហ៍មាន ១២ ម៉ោង (២ ម៉ោងសិក្សាអាចស្មើនឹង ១០០នាទី ) ។

-សៀវភៅសិក្សា កម្មវិធីសិក្សា គឺជាកម្មវិធី សៀវភៅសិក្សាដែលបានប្រកាសឱ្យប្រើប្រាស់ដោយក្រសួងអប់រំ យុវជន និងកីឡា។

## ១- កម្មវិធីសមមូលបឋមសិក្សា : (ថ្នាក់ទី៣ ដល់ ថ្នាក់ទី៦ )

-កម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធសមមូលនឹងកម្រិតបឋមសិក្សាអប់រំក្នុងប្រព័ន្ធ។

-សិក្សារយៈពេល ២ ឆ្នាំមានពី ៧០០ ម៉ោង ទៅ ៧៥០ ម៉ោង។

-កម្មវិធីលំអិត មានចែងក្នុងសៀវភៅកម្មវិធីសិក្សាគោលសម្រាប់កម្មវិធីសមមូលបឋមសិក្សារបស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ។

## ២- កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិ :

-កម្មវិធីសមមូល មធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ សមមូលនឹងកម្រិតមធ្យមសិក្សាបឋមភូមិអប់រំក្នុងប្រព័ន្ធ។

-សិក្សារយៈពេល ២ ឆ្នាំមានពី ៨០០ ម៉ោង ទៅ ៩៥០ ម៉ោង ។

-កម្មវិធីសិក្សាលំអិតមានចែងក្នុងសៀវភៅកម្មវិធីសិក្សាគោលសម្រាប់កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិរបស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ។

## ៣- កម្មវិធីសមមូលមធ្យមសិក្សាទុតិយភូមិ :

-កម្មវិធីសមមូលមធ្យមសិក្សាទុតិយភូមិអប់រំក្រៅប្រព័ន្ធសមមូលនឹងកម្រិតមធ្យមសិក្សាទុតិយភូមិអប់រំក្នុងប្រព័ន្ធ។

-សិក្សារយៈពេល ២ ឆ្នាំមានពី ៩៥០ ម៉ោង ទៅ ១១៤០ ម៉ោង ។

-កម្មវិធីសិក្សាលំអិតមានក្នុងសៀវភៅកម្មវិធីសិក្សាគោលសម្រាប់កម្មវិធីសមមូលមធ្យមសិក្សាទុតិយភូមិរបស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ។

## VI-ការរៀបចំសាលារៀនកម្មវិធីសមមូល

### ១- សាលារៀនកម្មវិធីសមមូល អាចជា ៖

-សាលារៀនចំណេះទូទៅ

-សាលាបំពេញវិជ្ជា

-មជ្ឈមណ្ឌលសិក្សាសហគមន៍

-រោងចក្រ សហគ្រាស

-មជ្ឈមណ្ឌលហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ

-នៅតាមទីកន្លែងណាមួយដែលសមស្រប ។

### ២- រយៈពេល និងថ្នាក់រៀនកម្មវិធីសមមូល ៖

ការសិក្សាក្នុងកម្មវិធីសមមូលអប់រំក្រៅប្រព័ន្ធត្រូវអនុវត្ត ៦ ឆ្នាំ ដោយចែកចេញជាបីកម្រិតគឺ ៖

ក- កម្រិតសមមូលបឋមសិក្សា ៖ សិក្សារយៈពេលពីរឆ្នាំ គឺឆ្នាំទី ១ និង ឆ្នាំទី ២ ។

ខ- កម្រិតសមមូលមធ្យមសិក្សាបឋមភូមិ ៖ សិក្សារយៈពេលពីរឆ្នាំ គឺឆ្នាំទី ១ និង ឆ្នាំទី ២ ។

គ- កម្រិតសមមូលមធ្យមសិក្សាទុតិយភូមិ ៖ សិក្សារយៈពេលពីរឆ្នាំ គឺឆ្នាំទី ១ និង ឆ្នាំទី ២ ។

### ៣- ការអនុញ្ញាតឱ្យបង្កើតសាលារៀន ៖

-ការបង្កើតសាលារៀនសមមូលបឋមសិក្សា សមមូលមធ្យមសិក្សា បឋមភូមិ និងសាលារៀនសមមូលមធ្យមសិក្សាទុតិយភូមិ ជាសមត្ថកិច្ចរបស់ក្រសួង អប់រំ យុវជន និងកីឡា ។

-បែបបទនៃការសុំបើកសាលាសមមូលមានចែងក្នុងសារាចរណែនាំ ។

## ៤- លក្ខខណ្ឌនៃការចូលរៀនរបស់សិស្ស ៖

### ៤-១ ៖ កម្រិតសមមូលបឋមសិក្សា ៖

ក- ថ្នាក់ឆ្នាំទី ១ ៖

-សិស្សទាំងពីរភេទដែលមានអាយុចាប់ពី ១២ ឆ្នាំឡើងត្រូវភ្ជាប់មកជាមួយនូវសំបុត្រកំណើត ឬសៀវភៅគ្រួសារ ។

-សិស្សទាំងពីរភេទដែលបានបញ្ចប់កម្មវិធីអក្ខរកម្ម ឬថ្នាក់ទី៣ នៃសាលាបឋមសិក្សារដ្ឋ និងឯកជន។

ខ- ថ្នាក់ឆ្នាំទី ២ ៖

-សិស្សទាំងពីរភេទដែលបានបញ្ចប់ការសិក្សាថ្នាក់ឆ្នាំទី ១ នៅកម្រិតសមមូលបឋមសិក្សា ឬបានបញ្ចប់ការសិក្សាថ្នាក់ទី ៤ នៃសាលាបឋមសិក្សារដ្ឋ និងឯកជន។

### ៤-២ ៖ កម្រិតសមមូលមធ្យមសិក្សាបឋមភូមិ ៖

ក- ថ្នាក់ឆ្នាំទី ១ ៖

-សិស្សទាំងពីរភេទដែលមានអាយុចាប់ពី ១៤ ឆ្នាំឡើងត្រូវភ្ជាប់មកជាមួយនូវសំបុត្រកំណើត ឬសៀវភៅគ្រួសារ និងលិខិតដែលមានបញ្ជាក់ការសិក្សាបញ្ចប់ឆ្នាំ ទី ២ នៅកម្រិតសមមូលបឋមសិក្សា ឬបានបញ្ចប់ការសិក្សាថ្នាក់ទី ៦ នៃសាលាបឋមសិក្សារដ្ឋ និងឯកជន។

ខ- ថ្នាក់ឆ្នាំទី ២ ៖

-សិស្សទាំងពីរភេទដែលបានបញ្ចប់ការសិក្សាឆ្នាំទី ១ នៅកម្រិតសមមូលមធ្យមសិក្សាបឋមភូមិ ឬបានបោះបង់ការសិក្សាថ្នាក់ទី ៨ នៃអនុវិទ្យាល័យរដ្ឋ និងឯកជន។

## ៤-៣ ៖ កម្រិតសមមូលមធ្យមសិក្សាទុតិយភូមិ ៖

ក- ថ្នាក់ឆ្នាំទី ១ ៖

-សិស្សទាំងពីរភេទ ដែលមានអាយុចាប់ពី ១៦ ឆ្នាំឡើង ត្រូវភ្ជាប់មកជាមួយនូវសំបុត្រកំណើត ឬសៀវភៅគ្រួសារ និងដែលមានសញ្ញាបត្រសមមូលមធ្យមសិក្សាបឋមភូមិ ឬសញ្ញាបត្រមធ្យមសិក្សាបឋមភូមិចំណេះទូទៅ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។

ខ- ថ្នាក់ឆ្នាំទី ២ ៖

-សិស្សទាំងពីរភេទដែលបានបញ្ចប់ការសិក្សានៅថ្នាក់ឆ្នាំទី ១ នៃកម្រិតសមមូល មធ្យមសិក្សាទុតិយភូមិ ឬដែលបានបោះបង់ការសិក្សានៅថ្នាក់ទី ១១ នៃវិទ្យាល័យរដ្ឋ និងឯកជន និងសិស្សដែលបានប្រឡងធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

-គ្រូបង្រៀន មន្ត្រីរាជការ កម្មករនិយោជិត និងកងកម្លាំងប្រដាប់អាវុធដែលមានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឬសញ្ញាបត្រ ដែលមានតម្លៃស្មើ និងបានចុះឈ្មោះចូលរៀននៅសាលារៀនសមមូល។

## ៥- គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន ៖

សមាសភាពគណៈគ្រប់គ្រង គ្រូបង្រៀន និងប្រាក់ឧបត្ថម្ភសម្រាប់សាលារៀនសមមូលបឋមសិក្សា សាលារៀនសមមូលមធ្យមសិក្សាបឋមភូមិ និងសមមូលមធ្យមសិក្សាទុតិយភូមិ មានចែងនៅក្នុងសេចក្ដីណែនាំដោយឡែករបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ៦- រូបភាពរៀនសូត្រ ៖

រូបភាពរៀនសូត្រត្រូវទន់ភ្លន់ និងតាមការជាក់ស្ដែង។

# ឧបសម្ព័ន្ធ

**កម្មវិធីក្រោយអក្ខរកម្ម :** ជាកម្មវិធីសម្រាប់ពង្រឹង និងពង្រីកចំណេះដឹង ដើម្បីឱ្យអ្នករៀនមានភាពស្ទាត់ជំនាញ ឬប៉ិនប្រសប់ក្នុងការដោះស្រាយបញ្ហានានា ដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់គេ។

**ការអប់រំបន្ត :** ការរៀនបន្ត បន្ទាប់ពីចេះអក្សរតិចតួច ( ការអប់រំបន្តមានកម្មវិធីជាច្រើន ដូចជាកម្មវិធីក្រោយអក្ខរកម្ម កម្មវិធីសមមូល កម្មវិធីបង្កើនប្រាក់ចំណូល កម្មវិធីកែលំអគុណភាពនៃជីវិត..)

**កម្មវិធីសមមូល :** គឺជាកម្មវិធីអប់រំក្រៅប្រព័ន្ធមួយដែលមានតម្លៃស្មើនឹងកម្មវិធីអប់រំក្នុងប្រព័ន្ធ។ ជាកម្មវិធីដែលជ្រើសសម្រាំងទាំងខ្លឹមសារ ទាំងមុខវិជ្ជាសំខាន់ៗពីកម្មវិធីសិក្សាអប់រំក្នុងប្រព័ន្ធ ដោយផ្សារភ្ជាប់នឹងកម្មវិធីបណ្តុះបណ្តាលមុខរបរ ។

**ពហុរូបភាព :** គឺជារូបភាព ឬមធ្យោបាយជាច្រើនសំរាប់រៀនសូត្រ គឺការរៀនសូត្រពេលណាក៏បាន អាស្រ័យលើគ្រូ និងក្រុមមុខសញ្ញា
ឧ : រៀនពេលព្រឹកក៏បាន ពេលថ្ងៃក៏បាន ពេលយប់ក៏បាន ថ្ងៃឈប់សម្រាកក៏បាន។

**ពហុវិស័យ :** សំដៅដល់ការអនុវត្តការងារអប់រំក្រៅប្រព័ន្ធមិនមែន តែក្រសួងអប់រំ យុវជន និងកីឡាតែមួយទេ គឺអនុវត្តគ្រប់ស្ថាប័ន ក្រុមហ៊ុនឯកជន អង្គការជាតិ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល។

**មជ្ឈមណ្ឌលសិក្សាសហគមន៍ :** មជ្ឈមណ្ឌលសិក្សាសហគមន៍ គឺជាមណ្ឌល (គ្រឹះស្ថាន)ដែលរៀបចំ និងគ្រប់គ្រងដោយប្រជាជននៅមូលដ្ឋានដើម្បីប្រជុំពិគ្រោះយោបល់ ទទួល និងផ្សព្វផ្សាយព័ត៌មាន ផ្តល់ចំណេះដឹងទូទៅ បណ្តុះបណ្តាលវិជ្ជាជីវៈ បង្កលក្ខណៈឱ្យប្រជាជនមានឱកាសបានរៀនសូត្រពេញមួយជីវិតសំដៅរួមចំណែកលើកកម្ពស់ជីវភាពរស់នៅទាំងស្មារតី និងសម្ភារៈ។

**ការសិក្សាពេញមួយជីវិត :** គឺជាការរៀនសូត្រផ្តើមតាំងពីការចាប់កំណើតរហូតដល់ស្លាប់។